៣-សេចក្តីសំរេចនេះធ្វើនៅ រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ១៩៩៨ នាសម័យប្រជុំពេញអង្គ នៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសំរេចស្ថាពរពិតប្រាកដ ។

ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ
ហត្ថលេខា និងត្រា
**ចាន់ សុខ**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
លេខាធិការ
**ម៉េង គីមលី**

★★★

ភ្នំពេញ ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ១៩៩៨

## សេចក្តីសំរេច លេខ ១១ កបធ/សសរ

## ក្រុមប្រឹក្សាធម្មនុញ្ញ

****

-បានឃើញថា : ចាប់ពីថ្ងៃបោះឆ្នោត និងរាប់សន្លឹកឆ្នោត ពុំមានពាក្យបណ្តឹងតវ៉ាណាមួយ ជាផ្លូវការពីគណបក្សហ្វ៊ុនស៊ិនប៉ិចមក គណៈកម្មការរៀបចំការបោះឆ្នោត ខេត្តកំពង់ចាម អំពីបំពាន ការសម្ងាត់ នៃការបោះឆ្នោត នៅឃុំអូរស្វាយ ស្រុកកំពង់សៀម ។

-បានឃើញថា : តាមឯកសារភស្តុតាងច្បាស់លាស់ពីការសំរេចរបស់គណៈប្រជាជន នៅភូមិអូរធ្នង់ ឃុំអូរស្វាយ ដើម្បីធ្វើជាការិយាល័យបោះឆ្នោត ព្រមទាំងបញ្ជាក់ថា ការិយាល័យបោះឆ្នោតភូមិអូរធ្នង់ លេខសំគាល់ ០៣០៥១០៩៩៨ ពិតជា [illegible] ដោយមានការចុះហត្ថលេខា ដោយតំណាងគណបក្សទាំងបួនរួមមាន គឺឈ្មោះ ម៉េង ប៉ូលី តំណាងគណបក្ស សម រង្ស៊ី ឈ្មោះ ម៉ៅ ម៉ុំ តំណាងគណបក្សហ្វ៊ុនស៊ិនប៉ិច ឈ្មោះ ម៉េត សាវឿន តំណាងគណបក្សខេមរភូមិន្ទ ឈ្មោះ ហេង ស្រ៊ុន តំណាងគណបក្សប្រជាជន រួចរាល់ស្របច្បាប់ហើយ ដូច្នេះបណ្តឹងតវ៉ារបស់គណបក្សហ្វ៊ុនស៊ិនប៉ិច ត្រូវអស់កម្មវត្ថុនិងមូលហេតុ ។

-បានឃើញថា : ពាក្យបណ្តឹងនេះគ្មានមូលការណ៍គ្រប់គ្រាន់ ដើម្បីបើកសវនាការតាមមាត្រា១១៧ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដើម្បីក្រុមប្រឹក្សាធម្មនុញ្ញសំរេចបដិសេធពុំទទួលពាក្យបណ្តឹងតវ៉ានេះ ។

-បានឃើញថា : សេចក្តីសំរេចលេខ ០៨-១៦១៥/៩៨ គជប ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ ១៩៩៨ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានហេតុផលត្រឹមត្រូវ ។

## សំរេច

១-បដិសេធពាក្យបណ្តឹងជំទាស់ លេខ ១៦២/៩៨ នពក ចុះថ្ងៃ ទី១១ ខែ សីហា ឆ្នាំ ១៩៩៨ របស់គណបក្សហ្វ៊ុនស៊ិនប៉ិច ដែលទាក់ទងនិងសេចក្តីសំរេច លេខ០៨-១៦១៥/៩៨ គជប ចុះថ្ងៃទី១១ ខែ សីហា ឆ្នាំ ១៩៩៨ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

២-តម្កល់សេចក្ដីសំរេច លេខ ០៨-១៦១៥/៩៨ គជប ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ១៩៩៨ របស់គណៈកម្មាធិការជាតិ រៀបចំការបោះឆ្នោត ទុកជាបានការពេញទាំងមូល ។

៣-សេចក្ដីសំរេចនេះធ្វើនៅ រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ១៩៩៨ នាសម័យប្រជុំពេញអង្គ នៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្ដីសំរេចស្ថាពរហាមប្ដឹងតវ៉ា ។

ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ
ហត្ថលេខា និងត្រា
**ចាន់ សុក**

ជាការត្រឹមត្រូវតាមច្បាប់ដើម
លេខាកត់ត្រា
**ម៉េង គឹមលី**

★★★

ភ្នំពេញ,ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ១៩៩៨

## សេចក្ដីសំរេច លេខ ១២ កបធ/សសរ

## ក្រុមប្រឹក្សាធម្មនុញ្ញ

****

-បានឃើញថា : ចាប់ពីថ្ងៃបោះឆ្នោត និងរាប់សន្លឹកឆ្នោត ពុំមានពាក្យបណ្ដឹងតវ៉ាណាមួយ ជាផ្លូវការពីគណបក្សហ្វ៊ុនស៊ិនប៉ិចមក គណៈកម្មការរៀបចំការបោះឆ្នោត ខេត្តកំពង់ចាម អំពីការរារាំងមិនអោយភ្នាក់ងារគណបក្សហ្វ៊ុនស៊ិនប៉ិច ចូលសង្កេតការណ៍ទាន់ពេលវេលា ។

-បានឃើញថា : តាមសេចក្ដីបញ្ជាក់របស់លោក ឌឹម សោភ័ណរ័ត្ន អនុប្រធានគណៈកម្មការរៀបចំការបោះឆ្នោតខេត្តកំពង់ចាម បានបញ្ជាក់ថា : ពុំមានការរារាំងដល់ភ្នាក់ងារគណបក្សណាមួយឡើយ ដើម្បីចូលសង្កេតការណ៍ ពីព្រោះមានការប្រជុំរាល់ថ្ងៃស្រាប់ ស្ដីពីវិធីបែបបទដែលភ្នាក់ងារគណបក្សត្រូវបំពេញ ដើម្បីអោយបានចូលរួមសង្កេតការណ៍ក្នុងការិយាល័យបោះឆ្នោត ហើយការប្រជុំនីមួយៗតែងតែមានតំណាងគណបក្ស និងតំណាងអង្គការជាច្រើនចូលរួម ពិសេសតំណាងគណបក្សហ្វ៊ុនស៊ិនប៉ិច និងអង្គការ Comfrel និង UN monitor ជាដើម ។ ការអះអាងរបស់លោក ឌឹម សោភ័ណរ័ត្ន ផ្អែកតាមកំណត់ហេតុនៃការប្រជុំ ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ១៩៩៨ និង កំណត់ហេតុប្រជុំ ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ១៩៩៨ ជាភស្ដុតាង ។

-បានឃើញថា : ពាក្យបណ្ដឹងនេះគ្មានបន្ទុកការណ៍គ្រប់គ្រាន់ ដើម្បីបើកសវនាការតាមមាត្រា១១៧ នៃច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ គប្បីក្រុមប្រឹក្សាធម្មនុញ្ញសំរេចបដិសេធពុំទទួលពាក្យបណ្ដឹងតវ៉ានេះ ។

-បានឃើញថា : សេចក្ដីសំរេចលេខ ០៨-១៦១២/៩៨ គជប ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ ១៩៩៨ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានលក្ខណៈត្រឹមត្រូវ ។